USAID
FROM THE AMERICAN PEOPLE

WINROCK INTERNATIONAL



គំរោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ ព្រឹត្តិប័ត្រ **អ្នកឆ្លាតវៃ** លេខ ១ ខែ មករា-មីនា ឆ្នាំ ២០១៣

## វិចារណកថា: ការគាំទ្រដ៏វៀងវៃ

អំពើជួញដូរមនុស្ស កើតឡើងនៅពេលដែលមនុស្សម្នាក់ត្រូវបានបង្ខំឱ្យធ្វើការងារ ដែលស្ថិតក្នុងស្ថានភាពកេងប្រវ័ញ្ច និងមិនអាចគេចចេញបានពីស្ថានភាពនោះ។ តាមធម្មតាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាជនក្រីក្រ ហើយធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើទាំងនៅក្នុងប្រទេសកម្ពុជា ឬឆ្លងកាត់ព្រំដែនទៅប្រទេសដ៏ទៃដើម្បីរកប្រាក់ចំណូលជួយផ្គត់ផ្គង់ជីវភាពគ្រួសារ។ ពួកគេមានជំនាញតិចតួចប៉ុន្តែត្រូវការប្រាក់ជាបន្ទាន់។ ពួកគេភាគច្រើន ស្វែងរកការងារជាកម្មករសំណង់ អ្នកបំរើតាមផ្ទះ ឬ ជាបុគ្គលិកធ្វើការងារតាមទីកន្លែងបំរើសេវាកំសាន្តនានា។ ពួកគេភាគច្រើនទទួលបានប្រាក់កំរៃតិចតួច មានករណីខ្លះមិនបានទទួលប្រាក់កំរៃអ្វីទាល់តែសោះ ព្រមទាំងត្រូវបានគេកេងប្រវ័ញ្ចទៀតផង។ ពួកគេមួយចំនួនអាចធ្លាក់ខ្លួនជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

តើអ្វីខ្លះដែលអាចបង្ការទប់ស្កាត់មនុស្ស ឱ្យរួចផុតពីអំពើជួញដូរមនុស្សបាន?

ការបង្កើតឱ្យមានការងារច្រើន ពិតជាអាចកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ លទ្ធភាពទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈដែលប្រសើរនឹងអាចឱ្យពលកររកការងារបានធ្វើ ហើយការផ្តល់ព័ត៌មានពីរបៀបនៃការធ្វើចំណាកស្រុកដោយសុវត្ថិភាព គឺជាជំនួយដល់ការយល់ដឹងរបស់ពួកគេក្នុងការកាត់បន្ថយនូវការប្រឈមនឹងការធ្លាក់ ក្នុងអំពើជួញដូរមនុស្ស។ ដំណើរការតាមដានហ្មត់ចត់ និងមានការកំណត់ត្រឹមត្រូវនៃការធ្វើចំណាកស្រុក ក៏អាចកាត់បន្ថយនូវគ្រោះថ្នាក់នេះបានដែរ។ ប៉ុន្តែវិធានការខាងលើនេះត្រូវការចំណាយពេលវេលា ហើយស្របពេលនេះផងដែរពលករនឹងនៅតែបន្តធ្វើចំណាកស្រុកដោយប្រថុយប្រថានមកកាន់រាជធានីភ្នំពេញ ឬទៅកាន់ប្រទេសថៃដើម្បីរកចំណូលឱ្យបានឆាប់រហ័ស។ យុទ្ធនាការទប់ស្កាត់ដែលមានបំណងប្រាប់ពលករមិនឱ្យធ្វើចំណាកស្រុកមិនអាចទប់ស្កាត់អំពើជួញដូរមនុស្សបានទេជាពិសេសនៅពេលដែលពួកគេគ្មានជំរើសផ្សេងទៀត។ ដូច្នេះការសំខាន់គឺត្រូវធ្វើការវិភាគពីតថភាព និងផ្តល់ព័ត៌មាន ព្រមទាំងជំនួយដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងដល់ពលករ។

ចំនុចសំខាន់មួយទៀតគឺត្រូវជួយឧបត្ថម្ភគាំទ្រដល់អ្នកដែលបានគេជួយសង្គ្រោះ ហើយដោយមិនត្រូវគ្រាន់តែបញ្ជូនគាត់ត្រឡប់ទៅស្រុកកំណើតវិញ ហើយទុកគាត់ចោលឱ្យប្រឈមនឹងអំពើជួញដូរម្តងទៀតឡើយ។អ្នកដែលបានគេជួយសង្គ្រោះ ហើយត្រូវការទទួលព័ត៌មានពីរបៀបធ្វើចំណាកស្រុកឡើងវិញដោយសុវត្ថិភាព ឬជំនួយក្នុងការស្វែងរកមុខរបរចិញ្ចឹមជីវិតដែលមានចីរភាព បើពុំនោះទេ ជំនួយទាំងអស់នឹងក្លាយជាអាសារបង់។

បើពលករត្រូវការភាពឆ្លាតវៀងវៃក្នុងការធ្វើចំណាកស្រុក កម្មវិធីទប់ស្កាត់អំពើអំពើជួញដូរមនុស្ស ក៏ត្រូវតែឆ្លាតវៀងវៃផងដែរ។

**ដោយលោកស្រី សារ៉ា ភីហ្សាណូ**
**នាយកកម្មវិធី ប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា របស់អង្គការវីនរ៉ក់ អន្តរជាតិ**

## កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (CTIP II) គឺជាគម្រោងដែលទទួលជំនួយឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកំលាំងពលកម្មនៅកម្ពុជា។ គម្រោងរយៈពេល៤ឆ្នាំនេះ (២០១១-២០១៥) ត្រូវបាននិង កំពុងអនុវត្តដោយអង្គការវីនរ៉ក់ អន្តរជាតិប្រចាំកម្ពុជា ដោយសហការជាមួយដៃគូរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា។ គម្រោងនេះ មានគោលបំណងធ្វើអោយប្រសើរឡើងនូវសមត្ថភាព និងភាពងាយស្រួលរបស់ស្ថាប័ននានា ក្នុងប្រទេសកម្ពុជាដើម្បី ប្រយុទ្ធប្រឆាំងរាល់ទម្រង់នានា នៃអំពើជួញដូរមនុស្ស តាមរយៈការទប់ស្កាត់អំពើជួញដូរមនុស្ស ធ្វើឱ្យប្រសើរឡើង នូវកិច្ចការពារជនរងគ្រោះ និងពលករចំណាកស្រុកព្រមទាំងជួយលើកកម្ពស់សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការផ្តន្ទាទោសជនល្មើស និងបទឧក្រិដ្ឋនានាដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ។

## សារជូនចំពោះមិត្តអ្នកអាន

សួស្តីប្រិយមិត្តអ្នកអានជាទីមេត្រី!

ព្រឹត្តប័ត្ររបស់អង្គការវីនរ៉ក់ ផលិតឡើងដើម្បីផ្តល់ពត៌មានដល់ពលករពលការិនី យុវជន និងសិស្សានុសិស្ស អំពីអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ក្នុងលេខនីមួយៗ យើងមានសំនួរសម្រាប់មិត្តអ្នកអាន។ បើសិនជាអ្នកមានអាយុក្រោម១៨ឆ្នាំសូមឆ្លើយសំណួរនៅទំព័រចុងក្រោយ ហើយផ្ញើចម្លើយរបស់អ្នកមកកាន់ ការិយាល័យរបស់អង្គការវីនរ៉ក់ តាមអាសយដ្ឋាន ដែលមាន នៅទំព័រចុងក្រោយ។ រាល់ព្រឹត្តប័ត្រដែលចេញគ្រប់លេខ ចម្លើយទាំងអស់ដែលផ្ញើមកនឹងបានចូលរួមចាប់រង្វាន់ ពីអង្គការវីនរ៉ក់។ អ្នកឈ្នះរង្វាន់៣នាក់ នឹង ទទួលរង្វាន់ ជាទឹកប្រាក់ចំនួន ៥០ដុល្លាអាមេរិក ។

## និយមន័យនៃអំពើជួញដូរមនុស្ស

មានការយល់ច្រលំជាច្រើន ពីនិយមន័យនៃអំពើជួញដូរមនុស្ស។ អ្នកខ្លះយល់ថា អំពើជួញដូរមនុស្ស គឺជាការរត់ពន្ធមនុស្ស ហើយខ្លះទៀតយល់ច្រឡំថាអំពើជួញដូរមនុស្សគឺ ការធ្វើចំណាកស្រុក។ ជំហានដំបូងគឺត្រូវយល់ពីគោលគំនិតផ្សេងៗឱ្យបានច្បាស់លាស់ ពីអំពើជួញដូរមនុស្ស និងធាតុផ្សំសំខាន់ៗអ្វីខ្លះ ដែលជួយយើងអាចកំណត់បានថាជាអំពើជួញដូរមនុស្ស ។

ច្បាប់កម្ពុជាស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើផ្លូវភេទមិនមានចែងអំពីនិយមន័យដែលមានលក្ខណៈទូលំទូលាយនោះទេ ប៉ុន្តែមាត្រាមួយចំនួននៃច្បាប់នេះបានចែងពីនិយមន័យនៃអំពើជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស។ មាត្រាទី១៣នៃច្បាប់នេះបានឱ្យនិយមន័យយ៉ាងច្បាស់លាស់ថាអំពើលក់ដូរមនុស្ស មានន័យថាប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬទទួលយកដោយខុសច្បាប់នូវការប្រគល់ការគ្រប់-គ្រងលើជនណាម្នាក់ពីជនដទៃដោយដោះដូរទៅនឹងរបស់មានតម្លៃអ្វីមួយដោយរាប់បញ្ចូលទាំងសេវា ទាំងនេះសុទ្ធតែចាត់ទុកថាជាអំពើជួញដូរមនុស្ស។ ច្បាប់នេះក៏បានចែងផងដែរនូវការលក់ដូរមនុស្ស សម្រាប់នាំឆ្លង -

ដែនទៅប្រទេសដទៃថាជាអំពើជួញដូរមនុស្សផងដែរ ។

យោងតាមទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) បានឱ្យដឹងថាអំពើជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មអន្តរជាតិដែលពាក់ព័ន្ធទៅនឹងការទទួលយកមនុស្សតាមរយៈការប្រើប្រាស់កំលាំងការបោកបញ្ឆោតការបង្ខិតបង្ខំ ក្នុងគោលបំណងកេងប្រវ័ញ្ចមនុស្សនោះ ដើម្បីទទួល យកផលប្រយោជន៍តាមរយៈការបង្ខំឱ្យធ្វើការងារធ្ងន់ធ្ងរ ឬ ធ្វើជាពេស្យាចារ ជា–ដើម ។

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២000 កិច្ចប្រជុំអង្គការសហប្រជាជាតិមួយ ត្រូវបានធ្វើឡើងនៅទីក្រុង ប៉ាឡឺម៉ូ ប្រទេស អ៊ីតាលីដើម្បីពិភាក្សាពីបញ្ហាការជួញដូរមនុស្ស។

កិច្ចប្រជុំនេះបានសម្រេចចេញជាពិធីសារ ដើម្បីបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការផ្តន្ទាទោសជនល្មើស។ ពិធីសារប៉ាឡឺម៉ូបានឱ្យនិយមន័យនៃអំពើជួញដូរមនុស្សដូចតទៅ: "ការជួញដូរមនុស្ស គឺជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងស្នាក់នៅ ឬការទទួល យកមនុស្សដោយមធ្យោបាយគំរាមកំហែង ឬប្រើកំលាំង ឬការបង្ខិតបង្ខំតាមរូបភាពផ្សេងៗ ដូចជាការចាប់ពង្រត់ ការក្លែងបន្លំ ការឆបោក ការរំលោភដោយអំណាច ឬតួនាទីលើជនដែលងាយរងគ្រោះ ឬ ការផ្តល់ ឬការទទួលជាលុយកាក់ ឬ ផលកម្រៃផ្សេងៗ ដើម្បីឱ្យមានការយល់ព្រមពីមនុស្សម្នាក់ដែលមានសិទ្ធិគ្រប់គ្រងលើជនម្នាក់ទៀត ក្នុងគោលបំណងកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចត្រូវបានរាប់បញ្ចូលទាំង ការកេងប្រវ័ញ្ចផ្លូវភេទលើអ្នកដទៃ ឬការកេងប្រវ័ញ្ចផ្លូវភេទតាមរូបភាពផ្សេងៗទៀត ការធ្វើការងារ ឬផ្តល់សេវាកម្មដោយបង្ខំ ការធ្វើជាទាសករ ឬការអនុវត្តដែលមានលក្ខណៈ ស្រដៀងគ្នាទៅនឹងទាស–ករ ភាពជាអ្នកបំរើដាច់ថ្លៃ ឬការលក់ដូរសរីរាង្គជាដើម "។ អំពើជួញដូរមនុស្សមានធាតុផ្សំ៣ :

១–ការផ្លាស់ទីមនុស្សណាម្នាក់

២–ដោយមានការបោកបញ្ឆោត ឬ ការបង្ខំ

៣–ឱ្យធ្លាក់ក្នុងស្ថានភាពការងារទាំងបង្ខំ ខ្ញុំកញ្ជះដាច់ថ្លៃ ឬការងារដែលស្រដៀងនឹងទាសភាពដោយរួមមានការបង្ខំឱ្យធ្វើជាស្រីពេស្យា និងការកេងប្រវ័ញ្ចផ្លូវភេទជាដើម ។

មាត្រាក្នុងច្បាប់របស់ប្រទេសកម្ពុជាស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិង អំពើធ្វើអាជីវកម្មផ្លូវភេទ បានគ្របដណ្តប់ទៅលើគ្រប់អំពើដែលបានចែងក្នុងពិធីសារប៉ាឡឺម៉ូដែរ ប៉ុន្តែវាឋិតនៅក្នុងមាត្រាផ្សេងគ្នា។ អំពើជួញដូរម–នុស្ស អាច កើតមានឡើងក្នុងឬក្រៅប្រទេស។

អំពើជួញដូរមនុស្ស អាចកើតមានឡើងទាំងក្នុងប្រទេស និងឆ្លងកាត់ព្រំដែន។ នៅក្នុងប្រទេស មនុស្សត្រូវបានគេជួញដូរពីជនបទ មកទីក្រុង ដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងធ្វើការងារដោយបង្ខំ ។ កុមារត្រូវបានជួញដូរ ដើម្បីបំរើការងារតាមផ្ទះ និងសុំទាន ។ គេជួញដូរមនុស្សឆ្លងកាត់ព្រំដែនដើម្បី កេងប្រវ័ញ្ចផ្លូវភេទ និងធ្វើពលកម្មដោយបង្ខំ។ ស្ត្រីបុរសនិងកុមារអាចធ្លាក់ខ្លួនក្លាយជាជនរងគ្រោះដោយអំពើជួញដូរ។ ការធ្វើចំណាកស្រុកមិនស្របច្បាប់ គឺមិនមែនជាអំពើជួញដូរមនុស្សទេហើយ–ជាទូទៅនៅក្នុងប្រទេសមួយ ករណីជួញដូរមនុស្សកើតមានឡើងចំនួនច្រើនជាងការជួញដូរមនុស្សឆ្លងកាត់ព្រំដែន។

ការធ្វើចំណាកស្រុកខុសច្បាប់ នាំមកនូវការប្រឈមក្នុងការធ្វើមាតុភូមិនិវត្តន៍ និងការទទួលបានប្រាក់ឈ្នួលមិនគ្រប់គ្រាន់ ដោយសារតែជាពលករខុសច្បាប់: ពួកគេត្រូវការមានជម្រើសក្នុងការធ្វើចំណាកស្រុកស្របច្បាប់ និង ធ្វើការងារប្រកបដោយសេចក្តីថ្លៃថ្នូរដែលទទួលបានប្រាក់កម្រៃត្រឹមត្រូវ។ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺ ជាជនចំណាកស្រុកដែលត្រូវគេបោកបញ្ឆោត ហើយពួកគេត្រូវការការជួយសង្គ្រោះឱ្យចេញផុតពីស្ថានភាព ការងារដូចទាសករ ។

ការរត់ពន្ធមនុស្ស គឺការទទួលប្រាក់ពីអ្នកណាម្នាក់ដើម្បីនាំ ឬផ្ទេរមនុស្សពីប្រទេសមួយទៅប្រទេសមួយដោយខុសច្បាប់។ អំពើនេះគឺពុំមានបំណងកេងប្រវ័ញ្ច –

លើមនុស្សពេលគេទៅដល់ប្រទេសគោលដៅនោះឡើយ។

បច្ចុប្បន្ន អង្គការមិនមែនរដ្ឋាភិបាលនានា និងរដ្ឋាភិបាល ជាពិសេសស្ថាប័នដែលធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សទូទាំងពិភពលោក បាននិងកំពុងប្រើប្រាស់និយមន័យរបស់ពិធីសារប៉ាឡឺម៉ូ ជាមូលដ្ឋានក្នុងការកំនត់បទល្មើសជួញដូរមនុស្ស ។។

## រួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

បើសិនជាអ្នកជួបប្រទះ ឬធ្លាក់ចូលក្នុងអំពើជួញដូរមនុស្ស អ្នកអាចស្នើសុំការជួយសង្គ្រោះពីប៉ូលីស តាមរយៈលេខទូរស័ព្ទដូចខាងក្រោម :

**ការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន:**

ការិយាល័យកណ្តាល: ០២៣ ៩៩ ៧៩ ១៩ ឬ ១២ ៨៨ (ហៅចូលមិនគិតថ្លៃ)

**ការិយាល័យដទៃទៀត:**

| | |
|---|---|
| ភ្នំពេញ: | ០១៧ ២៧៦ ២២២ |
| សៀមរាប: | ០១៧ ២៥៨ ២២២ |
| ព្រះសីហនុ: | ០១៧ ២៥៩ ២២២ |
| បាត់ដំបង: | ០១៧ ២៣៦ ២២២ |
| កំពង់ធំ: | ០១៧ ២៥៤ ២២២ |
| បន្ទាយមានជ័យ : | ០១៧ ២៦០ ២២២ |
| កំពង់ឆ្នាំង: | ០១៧ ៣២៦ ២២២ |

## ជនរងគ្រោះដោយអំពើជួញដូរ ៧នាក់ ត្រូវបានសង្គ្រោះនិងវិលត្រឡប់មកកម្ពុជាវិញ

កាលពីដើមឆ្នាំនេះ កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណាក់កាលទី២ តាមរយៈអង្គការដៃគូខារ៉ាម បាន សង្គ្រោះជនរង គ្រោះដោយអំពើជួញដូរមនុស្សចំនួន៧នាក់ពីប្រទេសម៉ាឡេស៊ី។ ជនរងគ្រោះទាំង ៧នាក់ មាននារី៥នាក់ និងកុមារី២នាក់។ ជនរងគ្រោះទាំង៧នាក់ ត្រូវបានស្ត្រីម្នាក់ លួងលោមឱ្យ ធ្វើចំណាកស្រុកទៅកាន់ ប្រទេសម៉ាឡេស៊ីដោយឆ្លងកាត់ប្រទេសថៃ ដើម្បីទៅធ្វើជាអ្នកបម្រើតាមផ្ទះ។ ស្ត្រីម្នាក់នោះនាំជនរងគ្រោះទាំង៧នាក់ ទៅកាន់ភ្នាក់ងារ មួយដែលគ្មានអត្តសញ្ញាណច្បាស់លាស់ នៅប្រទេសម៉ាឡេស៊ី។ យោងតាមសម្តីជនរងគ្រោះម្នាក់បានឱ្យដឹងថាភ្នាក់ងារនោះបានបង្ខំឱ្យពួកគេធ្វើ ការងារយ៉ាងធ្ងន់ធ្ងរអំឡុងពេលដែលពួកគេរង់ចាំថៅកែ មកទទួល–ពួកគេទៅធ្វើការ។ ភ្នាក់ងារនោះផ្តល់អាហារ ហូប–ចុកតែមួយពេលទេក្នុងមួយថ្ងៃ ហើយបានវាយក្បាលពួកគេលេងជាល្បែងទៀតផង ។

ជនរងគ្រោះទាំង៧នាក់បានរត់គេចចេញពីអគារចាក់សោររបស់ភ្នាក់ងារដោយឡើងតាមបំពង់ទឹក លួចផ្លោះរបងនៅពាក់កណ្តាលអធ្រាត្រ។ " *ក្រោយពីរត់គេចខ្លួនរួចយើងដើរដោយគ្មានទិសដៅច្បាស់លាស់។ខ្ញុំគិតថាម្តងនេះ ខ្ញុំពិតជាស្លាប់ហើយ ព្រោះខ្ញុំមិនបានស្គាល់អ្នកណាម្នាក់និងទីកន្លែងដែលត្រូវទៅនោះទេ។*នាងបានបន្តទៀតថាបន្ទាប់ពីពួកគេបានរត់គេចបាន៤ម៉ោងប៉ូលីសម្នាក់បានឃាត់ខ្លួនពួកគេហើយក៏បាននាំពួកគេទៅស្ថានទូត ខ្មែរ។

បច្ចុប្បន្នជនរងគ្រោះទាំង៧នាក់ បានវិលត្រឡប់ទៅរស់នៅជួបជុំគ្រួសាររបស់ពួកគេវិញ ក្នុងខេត្តកំពង់ចាម។ តាមច្បាប់កម្ពុជាជនរងគ្រោះមានសិទ្ធិប្តឹងស្ត្រីមេខ្យល់ដោយចោទពីបទប្រព្រឹត្តអំពើជួញដូរមនុស្ស។ ឈ្មួញជួញដូរមនុស្សអាចនឹងត្រូវផ្តន្ទាទោសនិងជាប់ពន្ធនាគារ

## តុលាការរាជធានីភ្នំពេញបើកសវនការករណីអំពើជួញដូរមនុស្ស

កាលពីថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៣ សាលាដំបូង-រាជធានីភ្នំពេញបានបើកសវនការ រឿងក្តីជួញដូរមនុស្សមួយ ដែលកើតឡើងកាលពីឆ្នាំមុន។ បុរសម្នាក់ និង មិត្តភ័ក្តិ៤នាក់ ទៀតត្រូវបានជនមួយក្រុមលួងលោម និងនាំពីខេត្តកំពង់ចាម មកស្នាក់នៅផ្ទះរបស់ខ្លួននៅភ្នំពេញ។ តែពេលមកដល់ផ្ទះ មួយ បុរសនោះនិងមិត្តភ័ក្ររបស់គាត់ដែលមានប្រុសម្នាក់ និងស្រី៣នាក់ ត្រូវបានជនមួយក្រុមនោះ បង្ខាំងទុកធ្វើ ទារុណកម្ម និងបង្ខំឱ្យប្រើប្រាស់គ្រឿងញៀនព្រមទាំងចាប់រំលោភមិត្តស្រីរបស់គាត់ម្នាក់ទៀតផង។

នៅថ្ងៃបន្ទាប់ គាត់បានរត់រួចចេញពីផ្ទះស្រែកឱ្យគេជួយ ហើយក្រុមប៉ូលីសក៏បានទៅដល់ហើយចាប់បានជនសង្ស័យ៥នាក់។ បក្សពួកមួយចំនួនទៀតបានរត់រួចពេលប៉ូលីសទៅដល់ ។

នៅក្នុងសវនការ ជនជាប់ចោទទាំង៥នាក់បានប្រកែកនៅចំពោះមុខតុលាការថាពួកគេមិនបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ខាងលើឡើយ។ពួកគេបានដាក់បន្ទុកទៅលើបក្សពួកមួយក្រុមទៀតដែលបានរត់បាត់។ ជនសង្ស័យទាំង៥បាននិយាយថា ពួកខ្លួនមិនបានដឹងថាបទល្មើសកើត ឡើងនៅលើផ្ទះរបស់ខ្លួនឡើយ។ ពួកគេនិយាយថា ពួកគេបានព្រមព្រៀងជាមួយជនរងគ្រោះដែលបានមកផ្ទះរបស់ពួកគេ ដើម្បីមករៀបចំពិធីសែនព្រេនតម្លើងរាសីនៅក្នុងផ្ទះ។ ពួកគេនិយាយថា ពួកគេត្រូវចំណាយលុយនៅក្នុងការព្រមព្រៀងនេះ។ ឥឡូវនេះសម្តីជនរងគ្រោះបានចោទប្រកាន់ទៅ កាន់បុគ្គលម្នាក់ក្នុងចំណោមជនសង្ស័យ ចំណែកតុលាការបានបើកសវនការកាត់ទោសចំនួន ២ ដង មក ហើយ ហើយការប្រកាសសាលក្រមនឹងធ្វើឡើងនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១៣ នេះ។

កម្មវិធីប្រឆាំងការជួញដូរមនុស្សនឹងបន្តជួយគាំទ្រដល់ជនរងគ្រោះនិងធានាឱ្យពួកគេទទួលបានយុត្តិធម៌ ។



ជនរងគ្រោះធ្វើការបន់ស្រន់មុនពេលចូលក្នុងបន្ទប់កាត់ក្តីនៅក្នុងតុលាការរាជធានីភ្នំពេញកាលពីថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០១៣

## យុវជនស្វែងយល់ពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព

ក្រុមយុវជនមួយក្រុម បានមកជួបជុំគ្នានៅវត្តមួយដើម្បីស្វែងយល់អំពីវិធីការពារខ្លួនឱ្យផុតពីអំពើជួញដូរមនុស្ស។ យុវជនមួយក្រុមដែលមានអាយុពី ១៤ ដល់ ៣០ ឆ្នាំ បានធ្វើដំណើរពីភូមិនានានៃខេត្តស្វាយរៀង ដើម្បីជួបជុំគ្នាក្នុងស្រុកស្វាយទៀប ដែលមានចំងាយ ៣០គ.ម. ពីទីរួមខេត្ត។ ពួកគេមិនបានយល់ដឹងពីអំពើជួញដូរមនុស្សទេ។ ជារឿយៗ ពួកគេច្រើនធ្វើចំណាកស្រុកទៅរកការ-ងារធ្វើបន្ទាប់ពីទំនេរពីការប្រមូលផល។

លោកណូ មីហ្សី ដែលជាអ្នកសម្របសម្រួល-ការបណ្តុះបណ្តាល និងក្រុមយុវជនរបស់គាត់ ដែលមកពីសមាគមន៍យុវជនខ្មែរ បានរៀបចំវគ្គបណ្តុះបណ្តាលដល់



យុវជនលេងល្បែងទាក់ទងនឹងការធ្វើចំណាកស្រុកដោយសុវត្ថិភាព

យុវជននៅខេត្តនានាក្នុងប្រទេសកម្ពុជា។ ពួកគេបានធ្វើដំណើរពីភ្នំពេញចុះទៅតាមភូមិដាច់ស្រយាលនានា ដើម្បីបង្រៀនយុវជននៅទីនោះ ឱ្យយល់ដឹងពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ។

ពួកគេបានបង្រៀនក្រុមយុវជនទាំងនោះ ឱ្យស្គាល់អត្តសញ្ញាណមេខ្យល់ ឈ្មួញជួញដូរមនុស្ស និងចេះប្រុងប្រយ័ត្នពីល្បិចកលបោកប្រាស់របស់ជនទាំងនោះ។ លោក ណូ មីស្សី បានមានប្រសាសន៍ថា "*យុវជនដែលជាពលករធ្វើចំណាកស្រុក ច្រើនតែធ្លាក់ខ្លួនចូលទៅក្នុងការងារជាទាសករ និងការកេងប្រវ័ញ្ចកំលាំងពលកម្ម ឬផ្លូវភេទ*" ។ អតីតអ្នកធ្វើចំណាកស្រុកពីរនាក់ បានចូលរួមចែករំលែកបទពិសោធន៍របស់ពួកគាត់ដល់អង្គប្រជុំ។ ពួកគាត់បានរៀបរាប់ពីរឿងរ៉ាវដែលកើតឡើងពេលដែលគាត់ធ្វើជាពលករចំណាកស្រុកទៅប្រទេសថៃ។ ពួកគាត់និយាយថាពលករមិនស្របច្បាប់ត្រូវបានប៉ូលីសថៃចាប់ឃុំឃាំង ឬត្រូវបានគេបង្ខំឱ្យធ្វើការងារធ្ងន់ធ្ងរដោយពុំទទួលបានប្រាក់កម្រៃឡើយ ។

លោក យូ ស៊ិន អតីតពលករចំណាកស្រុក បាននិយាយថា "មេខ្យល់ម្នាក់បានបោកខ្ញុំ។ គាត់ប្រាប់ខ្ញុំថា ខ្ញុំនឹងអាចរកប្រាក់បានច្រើន ប៉ុន្តែពេលខ្ញុំទៅដល់ទីនោះ វាជាការកុហកសោះ។ គេមិនបានឱ្យលុយខ្ញុំ ដូចគេសន្យាឡើយ។ ខ្ញុំទទួលបានប្រាក់កម្រៃតិចតួចបំផុត វាគ្រាន់តែគ្រប់សម្រាប់ការហូបចុកប៉ុណ្ណោះ។ ខ្ញុំត្រលប់មកដល់ផ្ទះវិញទាំងបាតដៃទទេ"។

អង្គការមិនមែនរដ្ឋាភិបាល បានប៉ាន់ប្រមាណថាមានប្រជាជនកម្ពុជាប្រហែលកន្លះលាននាក់បានធ្វើចំណាកស្រុកនិងកំពុងធ្វើការនៅក្រៅប្រទេស ។

ពួកគេភាគច្រើនមិនមានជំនាញការងារ ហើយពួកគេស្ទើរតែពាក់កណ្តាលបានធ្វើចំណាកស្រុកមិនស្របច្បាប់។ ការធ្វើចំណាកស្រុកអាចជាឱកាសមួយតែវាជាការចាំបាច់ណាស់ដែលអ្នកត្រូវមានពត៌មានឱ្យបានគ្រប់គ្រាន់មុនពេលចាកចេញ ព្រមទាំងយល់ដឹងពីការផ្សងគ្រោះថ្នាក់ និងវិធីជៀសវាងគ្រោះថ្នាក់ទាំងនោះ ។ ដើម្បីធ្វើចំណាកស្រុកស្វែងរកការងារ អ្នកត្រូវតែមានអាយុលើស ពី ១៨ ឆ្នាំ ហើយអ្នកត្រូវមានឯកសារគ្រប់គ្រាន់ ដូចជាលិខិតឆ្លងដែន ទិដ្ឋាការ (វីសា) និងលិខិតអនុញ្ញាតិការងារ ។

វាជាការចាំបាច់ណាស់ ដែលអ្នកត្រូវដឹងពីប្រទេសដែលអ្នកនឹងទៅព្រមទាំងត្រូវអានកិច្ចសន្យាការងារឱ្យបានច្បាស់លាស់មុនពេលចាកចេញទៅ។ អ្នកគួរតែរៀនសូត្រជំនាញនានានិងចេះភាសាខ្លះៗ : អ្នកធ្វើចំណាកស្រុកស្របច្បាប់ដែលមានជំនាញអាចនាំមកនូវប្រាក់ចំណូលដ៏ល្អ ខណៈ ពេលដែលអ្នកគ្មានជំនាញធ្វើចំណាកស្រុកមិនស្របច្បាប់ច្រើនតែខាតបង់ និងប្រឈមនឹងគ្រោះថ្នាក់នៃការកេងប្រវ័ញ្ច។ កាលពីឆ្នាំកន្លងទៅមានករណីជាច្រើនដែលស្ត្រីនិងកុមារី ធ្លាក់ក្នុងភាពជាទាសករបំរើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី។ នៅក្នុងប្រទេសកម្ពុជានៅតែមាន គ្រួ–សារដែល កំពុងស្វែងរកកូនស្រីរបស់ខ្លួន ប៉ុន្តែពួកគេបានបញ្ជូនកូនខ្លួន ទៅធ្វើការដោយពុំដឹងថាពួកគេត្រូវទៅទីណា និងដោយ ពុំបានស្វែងយល់ពីព័ត៌មានដែលផ្តល់ឱ្យដោយមេខ្យល់ដែលនាំមនុស្ស។ ឥឡូវនេះពួកគាត់ពុំមានវាសនានឹងរកឃើញកូនស្រីរបស់គាត់វិញទេ។ បុរសៗទទួលរងការឈឺចាប់ដោយធ្វើការនៅលើទូកនេសាទដោយពុំមានទទួលផលអ្វីសោះ ហើយពួកគេត្រូវរងការធ្វើទារុណកម្ម ចំណែកកុមារមួយចំនួន ត្រូវបានគេជួញដូរយកទៅសុំទាននៅប្រទេសវៀតណាម។

នៅក្នុងវគ្គបណ្ដុះបណ្ដាល យុវជនបានរៀនសូត្រពីការបង្ការខ្លួនកុំឱ្យធ្លាក់ក្នុងអំពើជួញដូរនិងរបៀបធ្វើចំណាកស្រុកដោយសុវត្ថិភាព និងរកបានចំណូលច្រើន។ យុវជនដែលបានចូលរួមរៀនសូត្រនឹងក្លាយជាអ្នកអប់រំបន្ត ដើម្បីផ្ញើសារបន្ត ដល់មិត្តភក្តិរបស់គេនៅក្នុងសហគមន៍។



ក្រុមយុវជនចូលរួមវគ្គសិក្សាស្ដីពីការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព

## ចំណុចគួរយល់ដឹងដើម្បីការពារខ្លួនកុំឱ្យធ្លាក់ក្នុងអំពើជួញដូរមនុស្ស : វាអាចជួយជីវិតអ្នកបាន!

- កុំឆាប់ជឿទុកចិត្តជនណាដែលសន្យាជួយរកការងារល្អដែលមានប្រាក់ខែច្រើន ឬឱ្យប្រាក់អ្នកដើម្បីធ្វើចំណាកស្រុក។ ភាគច្រើនវាជាអន្ទាក់ទេ។
- ពិគ្រោះយោបល់ជាមួយឪពុកម្ដាយ ចាស់ទុំ អ្នកមានចំណេះដឹង អាជ្ញាធរមូលដ្ឋាន និងអង្គការនានាដែលអ្នកស្គាល់។
- ពិនិត្យ និងស្វែងយល់ពីព័ត៌មានពីទីកន្លែងដែលយើងត្រូវទៅឱ្យបានច្បាស់លាស់សិនមុនធ្វើដំណើរ។
- ជម្រាបព័ត៌មានដល់ឪពុកម្ដាយ បងប្អូន ឬអាជ្ញាធរមូលដ្ឋានមុនពេលអ្នកទៅ ហើយត្រូវទុកអាស័យដ្ឋាន លេខទូរស័ព្ទទំនាក់ទំនង និងថតចម្លងទុកលិខិតឆ្លងដែន អត្តសញ្ញាណ - ប័ណ្ណ និងកិច្ចសន្យាការងារ។
- សុំឈ្មោះភ្នាក់ងារជ្រើសរើសពលករ ឬមេខ្យល់ ព្រមទាំងស្វែង រកព័ត៌មានមុនពេលចាកចេញ។
- ពេលចេញទៅត្រូវយកលុយខ្លះតាមខ្លួននិងលេខទូរសព្ទ័ជំ-នួយបន្ទាន់ ដោយព្យាយាមទន្ទេញលេខនោះឱ្យចាំមាត់។
- ត្រូវហ៊ានស្រែករកជំនួយ ឬ ប៉ុស្តិ៍ប៉ូលីស ឬ អង្គការណាមួយដែលនៅជិតអ្នក បើអ្នកមើលឃើញថាមិនស្រួល

## សំណួរ:

១–តើអ្នកធ្លាប់បានឮអំពីមនុស្សណាម្នាក់ដែលត្រូវបានគេជួញដូរនៅក្នុងភូមិរបស់អ្នកដែរឬទេ ? សូមរៀបរាប់ពីរឿងនោះប្រាប់ដល់យើង ។

២–តើអ្នកចង់ធ្វើចំណាកស្រុកដែរឬទេ? ទៅទីណាដែរ? ទៅធ្វើការងារអ្វី? តាមវិធីណា?

៣– តើនៅក្នុងភូមិរបស់អ្នកប្រជាពលរដ្ឋធ្វើចំណាកស្រុកតាមវិធីណា? ទៅទីណា? ទៅធ្វើអ្វី?

សូមដាក់ឈ្មោះអ្នក អាស័យដ្ឋាន និង លេខទូរស័ព្ទទំនាក់ទំនង របស់អ្នកហើយផ្ញើមកយើងឱ្យបានមុនថ្ងៃទី ៣០ ខែ–មិថុនា ឆ្នាំ២០១៣។ សូមអរគុណ!

បើសិនជាអ្នកជួបប្រទះឬធ្លាក់ចូលក្នុងអំពើជួញដូរមនុស្ស អ្នក អាចស្នើសុំការជួយសង្គ្រោះ តាមរយៈលេខទូរស័ព្ទដូចខាងក្រោម :

**នៅកម្ពុជា**

**អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ** (CWCC) ទូរស័ព្ទ : +855-23 99 79 67

**អង្គការខារ៉ាមកម្ពុជា** (CARAM)

ទូរស័ព្ទ : +855-23 21 80 65

**អង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី** (LSCW) ទូរស័ព្ទ : +855- 77 45 55 16

**ទូរស័ព្ទទំនាក់ទំនងនៅក្រៅប្រទេស**

ស្ថានទូតខ្មែរ នៅប្រទេសថៃ

(66) 29 575 851 ឬ (66)29 575 852

អង្គការ LPN នៅប្រទេសថៃ
(66)34 434 267

ស្ថានទូតខ្មែរ នៅប្រទេសម៉ាឡេស៊ី

(60)34 25 71 150 ឬ (60)34 25 73 711

អង្គការ TENAGANITA នៅម៉ាឡេស៊ី
(60) 37 770 3691

**របៀបហៅទូរស័ព្ទពីក្រៅប្រទេស:** វាយ 855 រួចវាយលេខដែលអ្នក ចង់ហៅដោយមិនបាច់ដាក់លេខ 0 ពីមុខទេ ។ ឧទាហរណ៍ យើងចង់វាយទៅលេខ 077 45 55 16 អ្នកគ្រាន់ តែចុច 855 77 455 516 ជាការស្រេច






អង្គការវីនរ៉ក់អន្តរជាតិបានចូលរួមជាមួយ រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល និង អ្នកពាក់ព័ន្ធនានា នៅក្នុងការទិវាជាតិប្រឆាំងការជួយដូរមនុស្ស (១២ ធ្នូ)

*" អង្គការវីនរ៉ក់អន្តរជាតិ ធ្វើការតាមរយៈដៃគូររបស់ខ្លួន ដោយមានការសហការណ៍ជាមួយ នាយកកដ្ឋានប្រឆាំងការជួយដូរមនុស្សនិងការពារអនិតិជននៃក្រសួងមហាផ្ទៃ បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីប៉ូលីស និងគាំទ្រ*

អង្គការវីនរ៉ក់អន្តរជាតិ ជាអង្គការមិនរកផលចំណេញ ដែលធ្វើការជាមួយប្រជាជនក្នុងសហរដ្ឋអាមេរិកនិងនៅទូទាំងពិភពលោកដើម្បីជួយដល់ជនក្រីក្រ បង្កើនឱកាសរកប្រាក់ចំណូល និងថែរក្សាធនធានធម្មជាតិអោយបានគង់វង្ស

WINROCK INTERNATIONAL

**ការិយាល័យអង្គការវីនរ៉ក់នៅប្រទេសកម្ពុជា**

មជ្ឈមណ្ឌលភ្នំពេញ អគារ អែហ្វ បន្ទប់លេខ ៧៨៧ មហាវិថី សុធារស រាជធានីភ្នំពេញ ទូរស័ព្ទ: +៨៥៥ (0)២៣ ២១២ ៣៣៤

ទូរសារ: +៨៥៥ (0) ២៣ ២១២ ៣៣៥ អ៊ីម៉េល: Cambodiaadmin@field.winrock.org គេហទំព័រ: www.winrock.org